សប្តាហ៍ទី 10

រឿងយ៉ាកុប ២

ស្តុប និងទេវតា

ព្រះជាម្ចាស់គង់នៅជាមួយលោកយ៉ាកុប!

រឿងក្នុងព្រះគម្ពីរ

លោកយ៉ាកុបចាកចេញពីក្រុងបៀរសេបាឆ្ពោះទៅកាន់ស្រុកហារ៉ែន។ ពេលថ្ងៃជិតលិច លោកបានទៅដល់កន្លែងមួយ ហើយស្នាក់នៅទីនោះ។ លោកបានយកថ្មមួយដុំមកកើយ រួចសម្រាន្តលក់ទៅ។
លោកសុបិនឃើញជណ្តើរមួយមានជណ្តើរមួយបញ្ឈរលើផែនដី ចុងវាខ្ពស់រហូតដល់មេឃ ហើយមានទេវទូតរបស់ព្រះជាម្ចាស់ នាំគ្នាឡើងចុះតាមជណ្តើរនោះ។ ហើយព្រះជាម្ចាស់មានព្រះបន្ទូលទៅយ៉ាកុប។
[លោកុប្បត្តិ ២៨:១០-១៥]

សមិទ្ធផលសម្រេច



វត្ថុបំណង

- ស្គាល់រឿងសុបិនលោកយ៉ាកុប
- ជឿថាព្រះជាម្ចាស់គង់ជាមួយលោកយ៉ាកុប
- ចងចាំព្រះបន្ទូល តាមរយៈការតុបតែងស្តុប និងទេវទូត។

សម្ភារៈ



របៀបធ្វើ

1 ការតុបតែងចានក្រដាស



តុបតែងមេឃ និងដីលើចានក្រដាស ដោយប្រើថ្នាំពណ៌។

2 ការតុបតែងយ៉ាកុប



ផាត់ពណ៌រូបភាពយ៉ាកុប បន្ទាប់មកកាត់យកទៅបិទលើចានក្រដាស។

3 ការតុបតែងស្តុប



បិទដុំថ្មតូចៗទៅនឹងចានក្រដាស ដោយប្រើស្តុត ឬការបិទឈើ ដើម្បីបង្កើតជាស្តុប។

4 ការបន្ថែមរូបទេវតា



គូររូបទេវតាដោយសេរី រួចផាត់ពណ៌។

5 ការសម្រេចសមិទ្ធផល



សូមបញ្ចប់ដោយកាត់រូបទេវតាបិទ រួចតុបតែងផ្កាយ និងពពក។

ការពង្រីកសកម្មភាព

- ការបង្កើតរូបរាងផ្សេងៗពីដុំថ្ម
  បង្កើតរូបរាងផ្សេងៗទៀតពីដុំថ្មដូចជាផ្ទះ ដើមឈើ ឈើឆ្កាងជាដើម។
- ការពិភាក្សាអំពីសេចក្តីដែលព្រះបានសន្យា
  ពិភាក្សាពីសេចក្តីសន្យាដែលព្រះបានសន្យាជាមួយលោកយ៉ាកុប។



Tip សម្រាប់គ្រូ

- សូមរៀបចំថ្មដែលតូចៗល្មម មិនធំពេក។
- នៅពេលកុមារបិទដុំថ្ម សូមជួយសង្កត់ដើម្បីឱ្យវាជាប់បានល្អ។
- ចំពោះរូបទេវតាវិញ ដោយសារតែវាមិនមានរូបរាងដែលពិតប្រាកដច្បាស់លាស់ណាមួយទេ ដូច្នេះសូមលើកទឹកចិត្តកុមារឱ្យគូរដោយសេរី។
- សូមប្រាប់ដល់កុមារ ថាថ្ងៃនេះផងដែរក៏ព្រះជាម្ចាស់គង់ជាមួយយើង ដូចជាទ្រង់គង់ជាមួយនឹងលោកយ៉ាកុបដែរ។